# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
អ្នកនាំពាក្យ គ.ជ.ប
លេខ ១៤៦ គ.ជ.ប

ថ្ងៃចន្ទ ៣រោច ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ ២០១៨

## សេចក្តីប្រកាសព័ត៌មាន

**អ្នកសង្កេតការណ៍អន្តរជាតិតំណាងប្រទេសចំនួន ៦ បានវាយតម្លៃថា**
**ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌**

បន្ទាប់ពីបានសង្កេតការណ៍នៅតាមការិយាល័យបោះឆ្នោតទាំងរាជធានីភ្នំពេញ និងតាមបណ្តាខេត្តមួយចំនួន អ្នកសង្កេតការណ៍អន្តរជាតិតំណាងឱ្យប្រទេសចំនួន ៦ បានចូលរួមក្នុងសន្និសីទសារព័ត៌មានសង្ខេបព្រឹត្តិការណ៍អំពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ក្រោមអធិបតីភាពឯកឧត្តម **ហង្ស ពុទ្ធា** សមាជិក និងជាអ្នកនាំពាក្យ គ.ជ.ប និងឯកឧត្តម **សោម សូរីដា** អគ្គលេខាធិការរង គ.ជ.ប នៅសណ្ឋាគារកាំបូឌីយ៉ាណា នាព្រឹកថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៨ ។

ប្រទេសទាំង ៦ នោះ រួមមាន ៖ ប្រទេសម៉ាឡេស៊ី ប្រទេសរុស្ស៊ី ប្រទេសឡាវ ប្រទេសឥណ្ឌា ប្រទេសថៃ និងប្រទេសវៀតណាម ។

ឯកឧត្តម **ហង្ស ពុទ្ធា** មានប្រសាសន៍ថា ការបោះឆ្នោត នីតិកាលទី៦ នេះ មានប្រជាពលរដ្ឋជាង ៨០% បានចេញទៅបោះឆ្នោត។ នេះបង្ហាញឱ្យឃើញថា ប្រជាពលរដ្ឋកម្ពុជាស្រលាញ់ និងត្រូវការលទ្ធិប្រជាធិបតេយ្យ ។ ឯកឧត្តមបន្ថែមថា ការប្រកាសលទ្ធផលនៃការបោះឆ្នោតត្រូវធ្វើឡើងជា ៤ ដំណាក់កាល ដូចខាងក្រោម ៖

- ការប្រកាសលទ្ធផលនៅតាមការិយាល័យបោះឆ្នោត
- ការប្រកាសលទ្ធផលបឋមនៃការបោះឆ្នោត
- ការប្រកាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត
- ការប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោត

តាមប្រតិទិនការងាររបស់ គ.ជ.ប ការប្រកាសលទ្ធផលបណ្តោះអាសន្នប្រសិនបើគ្មានបណ្តឹង នឹងត្រូវធ្វើឡើងនៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៨ ហើយការប្រកាសលទ្ធផលផ្លូវការនឹងត្រូវធ្វើឡើង នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨ ។ ប្រសិនបើមានបណ្តឹង គ.ជ.ប នឹងដោះស្រាយតាមនីតិវិធី ហើយលទ្ធផលផ្លូវការនឹងត្រូវប្រកាសយ៉ាងយូរត្រឹមថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៨។

តំណាងប្រទេសទាំង ៦ បានធ្វើចំណាប់អារម្មណ៍ម្នាក់ម្តងៗ ជារួម ពួកគាត់បានវាយតម្លៃថា ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ឆ្នាំ២០១៨ ប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ មានសន្តិសុខ សណ្តាប់ធ្នាប់ល្អ និងគ្មានអំពើហិង្សា ។

តំណាងប្រទេសឡាវ បានកត់សម្គាល់ថា ការបោះឆ្នោតនីតិកាលនេះ ល្អជាងនីតិកាលមុនទៅទៀត ជាពិសេសបញ្ជីឈ្មោះអ្នកបោះឆ្នោតត្រូវបានរៀបចំឡើងយ៉ាងល្អ ដោយមានភ្ជាប់ជាមួយរូបថតអ្នកបោះឆ្នោត ហើយសូម្បីតែប្រទេសថៃបញ្ជីឈ្មោះអ្នកបោះឆ្នោតក៏មិនបានរៀបចំបែបនេះដែរ។

ករណីនេះធ្វើឱ្យតំណាងប្រទេសឡាវ បានបញ្ជាក់យ៉ាងច្បាស់ថា គ.ជ.ប បានបំពេញតួនាទីរបស់ខ្លួនប្រកបដោយវិជ្ជាជីវៈ និងតម្លាភាព ។

ចំណែកឯតំណាងប្រទេសម៉ាឡេស៊ី បានលើកឡើងថា ការបោះឆ្នោតនៅកម្ពុជាពិតជាមានអ្នកចេញទៅបោះឆ្នោតច្រើនគួរឱ្យចាប់អារម្មណ៍។ ម៉្យាងទៀតប្រជាពលរដ្ឋចេញទៅបោះឆ្នោតដោយសប្បាយរីករាយ និងគ្មានការភ័យខ្លាច។ ជាងនេះទៅទៀតតំណាងប្រទេសម៉ាឡេស៊ី បានកត់សម្គាល់ថា ពេលបញ្ចប់ការបោះឆ្នោតនៅតាមការិយាល័យរាប់សន្លឹកឆ្នោតនីមួយៗ បានអនុញ្ញាតឱ្យមន្ត្រីបោះឆ្នោត ភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ អាចថតទិដ្ឋភាពដែលកំពុងរាប់សន្លឹកឆ្នោតបាន ដោយបញ្ជាក់ថា *"ចំណុចនេះ ប្រទេសម៉ាឡេស៊ី នឹងយកទៅរៀនសូត្រ"*។

បន្ទាប់ពីបានបញ្ចប់ការចាប់អារម្មណ៍របស់វាគ្មិន មានសំណួរមួយចំនួនបានលើកឡើងថា ៖

- ហេតុអ្វីបានជាកម្ពុជាមានចំនួនអ្នកចេញទៅបោះឆ្នោតច្រើន?
- តើសន្លឹកឆ្នោតមិនបានការមានចំនួនច្រើនប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោតដែរឬទេ?
- ការប្រកាសមិនទទួលស្គាល់លទ្ធផលនៃការបោះឆ្នោតពីប្រទេសមួយចំនួនដូចជា សហរដ្ឋអាមេរិកជាដើម តើអាចមានអ្វីកើតឡើង?

ឆ្លើយតបទៅនឹងសំណួរខាងលើ ឯកឧត្តម **សោម សូរីដា** អគ្គលេខាធិការរង គ.ជ.ប ពន្យល់ថា មូលហេតុដែលនាំឱ្យកម្ពុជាមានអ្នកចេញទៅបោះឆ្នោតមានចំនួនច្រើន ដោយសារ ៖

- កម្ពុជាមានសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ល្អ
- គ.ជ.ប បានប្រើប្រាស់គ្រប់មធ្យោបាយ ដើម្បីផ្សព្វផ្សាយព័ត៌មានដល់អ្នកបោះឆ្នោត
- ពលរដ្ឋខ្មែរស្រលាញ់ និងត្រូវការលទ្ធិប្រជាធិបតេយ្យ ។ល។

ចំពោះសន្លឹកឆ្នោតមិនបានការមានច្រើននៅនីតិកាលនេះ ឯកឧត្តម **សោម សូរីដា** ឆ្លើយថា " *គឺយើងត្រូវទទួលស្គាល់ទាំងអស់គ្នា ប៉ុន្តែសន្លឹកឆ្នោតមិនបានការក៏បានបង្ហាញឆន្ទៈរបស់ប្រជាពលរដ្ឋ ឆន្ទៈបែបណាយើងមិនអាចវាយតម្លៃបានទេ ការបោះឆ្នោតត្រូវធ្វើឡើងជាសម្ងាត់ ប្រការនេះគួរគណបក្សឈ្នះឆ្នោតយកទៅពិចារណា* "។

សំណួរចុងក្រោយ ឯកឧត្តម **ហង្ស ពុទ្ធា** ពន្យល់ថា ការវាយតម្លៃការបោះឆ្នោតនៅកម្ពុជា ដោយពាក់ព័ន្ធតាខ្មៅ ប្រាកដជាមើលទៅឃើញខ្មៅហើយ ចំពោះអ្នកដែលបានចូលរួមសង្កេតការណ៍បោះឆ្នោតនៅកម្ពុជាវិញ ពិតណាស់ពួកគេពិតជាបានមើលឃើញ អំពីលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ៕

**ចំពោះព័ត៌មានពិស្តារ សូមទាក់ទង!**


| | |
|---|---|
| ឯកឧត្តម **ហង្ស ពុទ្ធា** សមាជិក និងជាអ្នកនាំពាក្យ គ.ជ.ប<br>Tel: (855) 12 959 666<br>Email : hangputhea@gmail.com | ឯកឧត្តម **ឌឹម សុវណ្ណារ៉ុំ** សមាជិក និងជាអ្នកនាំពាក្យ គ.ជ.ប<br>Tel: (855) 12 518 485<br>Email : sovannaromhy@yahoo.fr |